**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**************

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៩១២ / ០៥.១១.២០១០

សាលដីកា

លេខ: ៧៥ ក្រ.III.ស/២៨.៩.២០១២

# តាមនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ:**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៩១២ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១០ រវាង៖

ជនជាប់ចោទឈ្មោះ [redacted]សុភា ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ មុខរបរៈកម្មករវាយថ្ម ទីលំនៅកំណើត និងទីលំនៅបច្ចុប្បន្ន [redacted] ស្រុកអង្គស្នួល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មិនមានកូន ទោសពីមុនគ្មាន។

មេធាវីការពារលោកស្រី [redacted] ម៉េងអ៊ាម។

ជាប់ចោទពីបទ: អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅ ភូមិគីរីថ្មី ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ: នស / រកម / ០២០៨ / ០០៥ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨។

ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីលក្ខ័ ហៅ [redacted] ស្រីលក្ខ័ ភេទស្រី អាយុ១៥ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted] ស្រុកអង្គស្នួល ខេត្តកណ្តាល។ ៚

## ដំណើររឿងមានដូចតទៅ៖

កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០៨ វេលាម៉ោង ១ និង៤០នាទីរសៀល ឈ្មោះ [redacted] ស្រីលក្ខ័ បានចូលក្នុងផ្ទះបន្ទប់បងស្រីខ្លួន ដើម្បីយកខោអាវស្លៀកពាក់ទៅរៀន, ពេលរកខោអាវបានហើយបំរុងបើកទ្វារចេញ ស្រាប់តែបងថ្លៃឈ្មោះ [redacted] សុភា បានចាប់ដៃទាញ ស្រីលក្ខ័ គ្រវាត់ទៅលើគ្រែយកក្រម៉ាញ៉ុកមាត់ រួចចាប់រំលោភរហូតបានសម្រេចតែម្តង។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៥ «ឃ» ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- កែប្រែបទចោទលើជនជាប់ចោទឈ្មោះ [redacted] សុភា ពីបទ រំលោភសេពសន្ថវៈ ទៅជាបទអំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅ ភូមិគីរីថ្មី ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

២- ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សុភា ភេទប្រុស អាយុ២០ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ (ប្រាំឆ្នាំ) គិតពីថ្ងៃចាប់ខ្លួន ពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០៨។

ពីបទ អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅ ភូមិគីរីថ្មី ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០៨។

បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខៈ នស / រកម / ០២០៨ / ០០៥ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨។

៣- បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] សុភា សងសំណងជំងឺចិត្តជាប្រាក់ចំនួន ២.០០០.០០០៛ (ពីរលានរៀល) ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីលក្ខ័ ហៅ [redacted] ស្រីលក្ខ័ គ្រប់ចំនួននៅពេលសាលក្រមចូលជាស្ថាពរ, ការទាមទារលើសពីនេះត្រូវលើកចោល។

ក្នុងករណីជនជាប់ចោទចចេសរឹងរូសពុំព្រមសង ត្រូវដាក់គុកបង្ខំដល់រូបកាយ ដើម្បីទារប្រាក់ធនទណ្ឌតាមច្បាប់។

៤- សាលក្រមនេះ ជំនុំជម្រះ នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៩ និងប្រកាសជាអសាធារណៈ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ នៅចំពោះមុខជនជាប់ចោទ, ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី។

បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ស្រីលក្ខ័ ជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៥ «ឃ» ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍។

បានឃើញ សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ក្រឡាបញ្ជី អានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]ស្រីលក្ខ័ ឆ្លើយនៅសាលាដំបូងខេត្តកណ្ដាល។

ជនជាប់ចោទឈ្មោះ [redacted]សុភា ឆ្លើយថា ក្នុងរឿងនេះ ខ្លួនមិនបានប្ដឹងឧទ្ធរណ៍ទេ ខ្លួនសុខចិត្តទទួលយកសេចក្ដីសម្រេច របស់សាលាដំបូងខេត្តកណ្ដាល។

## សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

រឿងនេះ ទាក់ទិននឹងបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើបណ្ដឹងអាជ្ញាមិនត្រឹមត្រូវទេ តាមមាត្រា ៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សូមសភាព្រហ្មទណ្ឌ ពិនិត្យ និងសម្រេច តាមច្បាប់។

ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទឈ្មោះ[redacted] សុភា,

ក្រោយពីបានស្ដាប់អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីលក្ខ័,

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សភាព្រហ្មទណ្ឌ

## យល់ឃើញថា:

១. បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ របស់ឈ្មោះ[redacted]ស្រីលក្ខ័ ជាដើមបណ្ដឹងរដ្ឋប្បវេណី ធ្វើនៅក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. តាមមាត្រា ៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បណ្ដឹងឧទ្ធរណ៍ធ្វើឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណី មានអានុភាពតែទៅលើសំណងរដ្ឋប្បវេណីប៉ុណ្ណោះ ដូច្នេះ សាលាឧទ្ធរណ៍មិនពិចារណាលើចំណុចផ្សេងទៀតនៃសាលក្រមឡើយ។

៣. ជនជាប់ចោទត្រូវបានសាលាដំបូងខេត្តកណ្ដាល សម្រេចផ្ដន្ទាទោស តាមសាលក្រមព្រហ្មទណ្ឌលេខ ១៥ «យ» ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ ពីបទ អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅ ភូមិគីរីថ្មី ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០៨ បទល្មើសមានចែងនិងឲ្យផ្ដន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដូច្នេះ ជនជាប់ចោទត្រូវទទួលជូសជុលសំណងព្យសនកម្ម, ហេតុនេះ គួរកែប្រែសំណងឲ្យបានសមស្រប។

៤. សាលក្រមព្រហ្មទណ្ឌលេខ ១៥ «យ» ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តកណ្ដាល សម្រេចត្រឹមត្រូវ គួរតម្កល់ទុកជាបានការ លើកលែងតែចំណុចទី៣ ស្ដីពីសំណងជំងឺចិត្ត គួរកែប្រែឲ្យបានសមស្រប ក្រៅពីនេះ គួរតម្កល់ទុកជាបានការដដែល។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្ដី

១. ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ស្រីលក្ខ័ ជាដើមបណ្ដឹងរដ្ឋប្បវេណី ទុកជាត្រឹមត្រូវតាមច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៥ «ឃ» ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តកណ្ដាល ទុកជាបានការ លើកលែងតែចំណុចទី៣ ស្ដីពីប្រាក់សំណងជំងឺចិត្ត ត្រូវកែពី ២.០០០.០០០៛ (ពីរលានរៀល) ទៅជា ៣.០០០.០០០៛ (បីលានរៀល) វិញ, ក្រៅពីនេះទុកនៅដដែល។

សាលដីកានេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវសាទុក្ខតាមច្បាប់។

**សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

..................................................................................................................................

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

យូ ប៊ុនឡេង

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី ០៤ ខែ ៦..... ឆ្នាំ ២០១៤
ក្រឡាបញ្ជី